ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ ៧-០២-១២៧ ប្រក

# ប្រកាស
## ស្តីពី
## វិសោធនកម្មលើប្រកាសលេខ ធ ៧-០១-១៣៧ ប្រក
## ស្តីពី
## ឥណទានចំពោះសម្ព័ន្ធញាតិ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/ ២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/ ១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/ ០៣៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- បានឃើញប្រកាសលេខ ធ ៧-០១-១៣៧ ប្រក ស្តីពីឥណទានចំពោះសម្ព័ន្ធញាតិ
- យោងតាមស្មារតីនៃការប្រជុំក្រុមការងារផ្នែកសេវាកម្មធនាគារនិងហិរញ្ញវត្ថុជាមួយវិស័យឯកជន នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០២

## សំរេច

**ប្រការ ១ :**

ធ្វើវិសោធនកម្មប្រការ៤ នៃប្រកាសលេខ ធ ៧-០១-១៣៧ ប្រក ស្តីពីឥណទានចំពោះសម្ព័ន្ធញាតិ ដែលមានខ្លឹមសារដូចខាងក្រោម ៖

សរុបឥណទានដក់សល់ថ្លឹងចំពោះសម្ព័ន្ធញាតិមិនត្រូវអោយលើសពី ១០% នៃមូលនិធិផ្ទាល់សុទ្ធទេ ទោះជាក្នុងករណីណាក៏ដោយ ។ ការគណនាឥណទានសម្ព័ន្ធញាតិមិនត្រូវរួមបញ្ចូលការតំកល់ប្រាក់នៅទីស្នាក់ការកណ្តាល រឺនៅក្រុមហ៊ុនមេ ក្រោមល័ក្ខខ័ណ្ឌពីរដូចខាងក្រោម ÷

- ទីស្នាក់ការកណ្តាល ឬ ក្រុមហ៊ុនមេជាធនាគារ
- ត្រូវមានភស្តុតាងបង្ហាញថាធនាគារមានចំណាត់ថ្នាក់ស្មើ ឬខ្ពស់ជាង A តាមវិធីសាស្រ្ត Standard & Poor ឬតាមវិធីសាស្រ្តសមមូលដោយភ្នាក់ងារចាត់ថ្នាក់ដែលអន្តរជាតិទទួលស្គាល់ ។

ឥណទានដក់សល់ត្រូវគណនាទៅតាមប្រកាសស្តីពីអនុបាតសាធនភាព ( ប្រកាសបច្ចុប្បន្នលេខ ធ ៧-០០-៤៦ ប្រក ) ។

មូលនិធិផ្ទាល់សុទ្ធរបស់ធនាគារត្រូវគណនាស្របតាមប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ( ប្រកាសបច្ចុប្បន្ន លេខ ធ ៧-០០-៤៧ ប្រក ) ។

**ប្រការ ២ :**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ៣ :**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០០២

ទេសាភិបាល

ជា-ចាន់តូ

**កន្លែងទទួល**

- ដូចប្រការ ២ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"